**This little booklet in Cambodian/Khmer called**

# Do You Want To Know God Personally?




## ព្រះ GOD

ព្រះទ្រង់ជាវិញ្ញាណ។ ទ្រង់មានវត្តមានគង់នៅគ្រប់ទីកន្លែង ទាំងនៅលើផែនដី និងស្ថានសួគ៌ ជាមួយគ្នាទ្រង់ក៏គង់នៅអស់កល្បជានិច្ចដែរ។ ទ្រង់ជាព្រះដ៏មានអំណាចចេស្តាជាព្រះអាទិករ ដែលបានបង្កើតគ្រប់របស់សព្វសារពើទាំងអស់នៅលើផែនដី និងចក្រវាលទាំងមូល។ ទ្រង់ជ្រាបគ្រប់ការទាំងអស់ ទ្រង់គ្រប់គ្រងថែរក្សា ហើយការពារនូវរាល់ជីវិត ទាំងនៅលើផែនដី ក៏ដូចជាចក្រវាលទាំងមូលដោយរាជអំណាចរបស់ទ្រង់ ។

ទ្រង់ជាព្រះបរិសុទ្ធ សុចរិត យុត្តិធម៌ ហើយពោរពេញដោយសេចក្តីស្រឡាញ់។ ទ្រង់ស្រឡាញ់មនុស្សលោក ទោះបើមនុស្សមានបាបដោយមិនស្តាប់បង្គាប់ ហើយបដិសេធទ្រង់យ៉ាងណាក៏ដោយ។ ព្រះទ្រង់បានបង្ហាញសេចក្តីស្រឡាញ់របស់ទ្រង់តាមរយៈព្រះយេស៊ូវគ្រីស្ទក្នុងគោលបំណងសង្គ្រោះមនុស្សឱ្យរួចពីអំពើបាប ហើយនាំមនុស្សឱ្យវិលត្រឡប់មកឯព្រះអង្គវិញ។

អង្គការនិស្សិតនិងប្រជាជនកម្ពុជាសំរាប់ព្រះគ្រីស្ទ

តទៅនេះគឺជាគោលការណ៍ទាំងបួនយ៉ាងដែលនឹងជួយឱ្យអ្នកអាចរកឃើញថា តើធ្វើដូចម្តេចដើម្បីស្គាល់ព្រះដោយផ្ទាល់ខ្លួន និងដកពិសោធន៍នូវជីវិតពេញបរិបូរណ៍ ដែលទ្រង់បានសន្យា។

**1 ព្រះស្រឡាញ់អ្នក (ទ្រង់បានបង្កើតអ្នក) ហើយទ្រង់ចង់ឱ្យអ្នកមានទំនាក់ទំនង ដោយផ្ទាល់ជាមួយទ្រង់ ៗ**

**សេចក្តីស្រឡាញ់នៃព្រះ**

*«ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម៉្លេះ បានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែមួយដើម្បីឱ្យអ្នកណា ដែលជឿដល់ព្រះរាជបុត្រានោះមិនត្រូវវិនាសឡើយ គឺឱ្យមានជីវិតអស់កល្បជានិច្ចវិញ»*
*(យ៉ូហាន ៣:១៦)*

**ផែនការរបស់ព្រះ**

«នេះជាជីវិតដ៏នៅអស់កល្បជានិច្ច គឺឱ្យគេបានស្គាល់ដល់ទ្រង់ដ៏ជាព្រះពិតតែ១ និងព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់បានចាត់ឱ្យមកផង»
*(យ៉ូហាន ១៧:៣)*

➤ *តើមានការអ្វីខ្លះដែលរារាំងអ្នកមិនឱ្យស្គាល់ព្រះដោយផ្ទាល់ខ្លួន?*

៣

មនុស្សមានបាប ហើយដាច់ចេញពីព្រះ ដូច្នេះគេមិនអាចស្គាល់ទ្រង់ ឬជកពិសោធន៍នូវសេចក្ដីស្រឡាញ់ និងផែនការដ៏អស្ចារ្យរបស់ទ្រង់បានឡើយ ។

## 2 មនុស្សមានបាប

*«ពីព្រោះគ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ» (រ៉ូម៣:២៣)*

ព្រះបានបង្កើតមនុស្សមក សំរាប់ប្រកបទាក់ទងនឹងព្រះអង្គ ប៉ុន្តែដោយការរឹងចចេសតាមបំណងអាត្មានិយម គេក៏បានប្រព្រឹត្តតាមតែចិត្តរបស់គេ ហើយចំណងនៃការទាក់ទងនឹងព្រះក៏ត្រូវកាត់ផ្ដាច់។ បំណងអាត្មានិយមនេះ ដែលសម្ដែងឱ្យឃើញច្បាស់ដោយសារការបះបោរយ៉ាងសកម្ម ឬការព្រងើយកន្ដើយជាភស្ដុតាងមួយដែលព្រះគម្ពីរហៅថា «បាប»។

### មនុស្សបានដាច់ចេញពីព្រះ

«ដ្បិតឈ្នួលរបស់អំពើបាប នោះជាសេចក្ដីស្លាប់» (ព្រលឹងវិញ្ញាណដាច់ចេញពីព្រះ) (រ៉ូម៦:២៣)








ព្រះទ្រង់បរិសុទ្ធ ឯមនុស្សវិញមានពេញដោយអំពើបាប។ មានជ្រោះដ៏ជ្រៅមួយ ដែលកាត់ផ្ដាច់រវាងមនុស្ស និងព្រះអង្គ។ មនុស្សខំប្រឹងជានិច្ចដើម្បីឈោងរកព្រះ និងជីវិតដ៏ពេញបរិបូណ៌ ដោយពឹងលើកំលាំងផ្ទាល់ខ្លួនដូចជា: ខំរស់នៅឱ្យបានល្អ ខំសា្វធ្យាយសីលធម៌ រៀនទស្សនវិជ្ជា ឬកាន់សាសនា ។ល។

➤ *គោលការណ៍ទីបីនឹងពន្យល់នូវមធ្យោបាយតែមួយគត់ដើម្បីឆ្លងជ្រោះដ៏ជ្រៅនេះ...*





## 3 ព្រះយេស៊ូវគ្រីស្ទជាចំលើយ តែមួយគត់របស់ព្រះចំពោះបាបកម្មនៃមនុស្សលោកខ ដោយសារទ្រង់ នោះអ្នកអាចស្គាល់ និងពិសោធន៍នូវសេចក្ដីស្រឡាញ់ និងផែនការរបស់ព្រះសម្រាប់ជីវិតរបស់អ្នកខ

### ព្រះអង្គសុគតជំនួសយើង

«តែឯព្រះ ទ្រង់សំដែងសេចក្ដីស្រឡាញ់របស់ទ្រង់ដល់យើងរាល់គ្នាឱ្យឃើញច្បាស់ ដោយព្រះគ្រីស្ទសុគតជំនួសយើងរាល់គ្នា នោះគឺក្នុងកាលដែលយើងនៅមានបាបនៅឡើយផង» (រ៉ូម៥:៨)

### ព្រះអង្គរស់ពីសុគតឡើងវិញ

«ព្រះគ្រីស្ទបានសុគតដោយព្រោះបាបយើងរាល់គ្នា ...ទ្រង់ត្រូវគេបញ្ចុះក្នុងផ្នូរ...រួចដល់ថ្ងៃទីបីនោះទ្រង់មានព្រះជន្មរស់ឡើងវិញក៏តាមបទគម្ពីរ...ទ្រង់លេចឱ្យពេត្រុសឃើញ រួចដល់ពួក១២នាក់ដែរ ក្រោយទៀតទ្រង់លេចមកឱ្យពួកបងប្អូនជាង៥០០នាក់ឃើញតែម្ដង» (១កូរិនថូស១៥:៣_៦)។



### ព្រះអង្គជាផ្លូវតែមួយគត់ដែលនាំយើងទៅឯព្រះ

ព្រះយេស៊ូវមានបន្ទូលថា: *«ខ្ញុំជាផ្លូវ ជាសេចក្ដីពិត ហើយជាជីវិត បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ»* (យ៉ូហាន១៤:៦)។




ព្រះទ្រង់ដាក់ស្ពានមួយ ឆ្លងជ្រោះដ៏ជ្រៅ ដែលកាត់ផ្ដាច់យើងចេញពីព្រះអង្គ គឺដោយចាត់ព្រះរាជបុត្រាទ្រង់ ព្រះនាមព្រះយេស៊ូវគ្រីស្ទ ឱ្យយាងមកដើម្បីសុគតលើឈើឆ្កាងជំនួសបាបយើងរាល់គ្នា។

➤ បើគ្រាន់តែស្គាល់គោលការណ៍ទាំងបីប្រការនេះក៏នៅតែមិនគ្រប់គ្រាន់ដែរ...

## 4 យើងម្នាក់ៗត្រូវតែទទួលព្រះយេស៊ូវគ្រីស្ទដោយផ្ទាល់ខ្លួនទុកជាព្រះអង្គសង្គ្រោះ និងជាព្រះអម្ចាស់របស់យើង ទើបយើងអាចស្គាល់ព្រះ ហើយពិសោធន៍នូវសេចក្ដីស្រឡាញ់ និងផែនការរបស់ព្រះ សំរាប់ជីវិតយើងខ

### យើងត្រូវតែទទួលព្រះយេស៊ូវគ្រីស្ទ

«ប៉ុន្តែអស់អ្នកណាដែលទទួលទ្រង់ គឺអស់អ្នកដែលជឿដល់ព្រះនាមទ្រង់ នោះទ្រង់បានប្រទានអំណាចឱ្យបានត្រឡប់ជាកូនព្រះ» (យ៉ូហាន១:១២)

### យើងទទួលព្រះយេស៊ូវគ្រីស្ទដោយសារជំនឿ

«ដ្បិតគឺដោយព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះដោយសារសេចក្ដីជំនឿ ហើយសេចក្ដីនោះក៏មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ ក៏មិនមែនដោយការប្រព្រឹត្តិដែរ ក្រែងអ្នកណាអួតខ្លួន» ។ (អេភេសូរ ២:៨_៩)

*នៅពេលដែលយើងទទួលព្រះគ្រីស្ទ យើងពិសោធន៍នូវកំណើតថ្មី*

សូមអាន (យ៉ូហាន៣:១_៨)។



### យើងទទួលព្រះគ្រីស្ទដោយផ្ទាល់ខ្លួន

ព្រះយេស៊ូវមានបន្ទូលថា ÷ «*មើល! ខ្ញុំឈរនៅមាត់ទ្វារទាំងគោះ បើអ្នកណាឮសំលេងខ្ញុំហើយបើកទ្វារឱ្យ នោះខ្ញុំនឹងចូលទៅឯអ្នកនោះ*»។ (*វិវរណៈ ៣:២០*)

ការទទួលព្រះគ្រីស្ទគឺជាការបែរចេញពីអាត្មាអញមកឯព្រះ (ការផ្លាស់ប្រែ) ហើយទុកចិត្តព្រះគ្រីស្ទឱ្យព្រះអង្គយាងចូលមក ក្នុងជីវិតយើង ដើម្បីអត់ទោសបាប ហើយច្នៃជីវិតយើងទៅតាមព្រះហឫទ័យព្រះអង្គ។ បើគ្រាន់តែយល់ព្រមដោយប្រាជ្ញាថា ព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រានៃព្រះ ហើយថាទ្រង់បានសុគតនៅលើឈើឆ្កាងជំនួសអំពើបាបរបស់យើងរាល់គ្នា នោះមិនគ្រប់គ្រាន់ទេ។ ហើយដែលមានការពិសោធន៍ខាងអារម្មណ៍នោះក៏នៅតែមិនគ្រប់គ្រាន់ដែរ។ យើងទទួលព្រះយេស៊ូវគ្រីស្ទដោយសារជំនឿ ដែលជាសកម្មភាពនៃបំណងចិត្ត។

**រង្វង់ទាំងពីរនេះ បង្ហាញពីជីវិតពីរប្រភេទ**

**ជីវិតដែលអញនិយមត្រួតត្រា**

អាត្មាអញនៅលើបល្ល័ង្គ
ព្រះគ្រីស្ទនៅក្រៅជីវិត
ជីវិតដែលដឹកនាំដោយខ្លួនឯង
តែងនាំឱ្យមានការរកាំរកូសនិងការខកចិត្ត។




**ជីវិតដែលព្រះគ្រីស្ទត្រួតត្រា**

ព្រះគ្រីស្ទគង់នៅលើបល្ល័ង្គនៃជីវិត
អាត្មាអញចុះចេញពីបល្ល័ង្គ
ជីវិតដែលដឹកនាំដោយ
សារព្រះតែងសមស្របតាមផែនការរបស់ទ្រង់យ៉ាងត្រឹមត្រូវ។

តើរង្វង់ណាមួយដែលតំណាងពីជីវិតរបស់អ្នក?
តើអ្នកចង់បានរង្វង់ណាមួយជាតំណាងសំរាប់ជីវិតអ្នក?

➤ តទៅនេះនឹងប្រាប់ពីរបៀបដែលអ្នកអាចទទួលព្រះគ្រីស្ទ ...



### អ្នកអាចទទួលព្រះគ្រីស្ទឥឡូវនេះបានដោយអធិស្ឋាន

*(ការអធិស្ឋាន គឺជាការនិយាយជាមួយព្រះ)*

ព្រះទ្រង់ស្គាល់ចិត្តអ្នក ហើយទ្រង់មិនរាប់ជាសំខាន់ លើពាក្យសំដីអ្នកទេ ព្រោះទ្រង់សព្វព្រះហឫទ័យលើចិត្តអ្នកវិញ ។
តទៅនេះ ជាលំនាំនៃសេចក្ដីអធិស្ឋានដោយជំនឿ ÷

*«ព្រះអម្ចាស់យេស៊ូវអើយ ខ្ញុំត្រូវការព្រះអង្គ។ អរគុណព្រះអង្គ ដែលបានសុគតនៅលើឈើឆ្កាងជំនួសអំពើបាបខ្ញុំ។ ខ្ញុំសូមបើកទ្វារជីវិតខ្ញុំ ទទួលព្រះអង្គធ្វើជាព្រះអង្គសង្គ្រោះ និងជាព្រះអម្ចាស់របស់ខ្ញុំ។ អរគុណព្រះអង្គដែលបានអត់ទោសបាបឱ្យខ្ញុំ ហើយប្រទានជីវិតអស់កល្បជានិច្ចដល់ខ្ញុំ។ សូមទ្រង់យាងមកសោយរាជ្យ លើបល្ល័ង្គជីវិតខ្ញុំ។ សូមកែច្នៃខ្ញុំឱ្យទៅជាមនុស្ស ដែលព្រះអង្គសព្វព្រះហឫទ័យ» អាម៉ែន។*

តើអ្នកចង់អធិស្ឋានតាមលំនាំខាងលើ ដើម្បីយាងព្រះគ្រីស្ទមកគង់ក្នុងជីវិតអ្នកក្នុងពេលឥឡូវនេះឬទេ?



### ធ្វើដូចម្ដេចឱ្យដឹងថាព្រះគ្រីស្ទគង់ក្នុងជីវិតអ្នក

ដែលអ្នកបានអធិស្ឋាន តើអ្នកបានទទួលព្រះគ្រីស្ទមកគង់ក្នុងជីវិតអ្នកហើយឬនៅ? តាមព្រះបន្ទូលសន្យារបស់ទ្រង់ក្នុងគម្ពីរ (វិវរណៈ៣:២០) តើឥឡូវនេះ ព្រះគ្រីស្ទទ្រង់គង់នៅត្រង់ណាក្នុងការទាក់ទងជាមួយអ្នក? ព្រះគ្រីស្ទមានបន្ទូលថា ព្រះអង្គនឹងយាងចូលមកក្នុងជីវិតអ្នក តើព្រះអង្គកុហកអ្នកឬ? តើដោយសំអាងលើអ្វី ដែលឱ្យអ្នកដឹងថាព្រះបានឆ្លើយទៅនឹងសេចក្ដីអធិស្ឋានរបស់អ្នក? (ការទុកចិត្តលើព្រះផ្ទាល់ និងលើព្រះបន្ទូលសន្យារបស់ទ្រង់ គឺព្រះគម្ពីរប៊ីប)។

### ព្រះគម្ពីរប៊ីបសន្យានឹងផ្ដល់នូវជីវិតអស់កល្បជានិច្ចដល់អ្នកដែលទទួលព្រះគ្រីស្ទ

«នេះហើយជាសេចក្ដីបន្ទាល់នោះ គឺថាព្រះទ្រង់បានប្រទានជីវិតដ៏នៅអស់កល្បជានិច្ចមកយើងរាល់គ្នា ហើយជីវិតនោះគឺនៅក្នុងព្រះរាជបុត្រានៃទ្រង់។ ឯអ្នកណាដែលមានព្រះរាជបុត្រានោះ ក៏មានជីវិតដែរ តែអ្នកណាដែលគ្មានព្រះរាជបុត្រានៃព្រះទេ នោះគ្មានជីវិតឡើយ ។ ខ្ញុំបានសរសេរសេចក្ដីទាំងនេះផ្ញើមកអ្នករាល់គ្នា ដែលជឿដល់ព្រះនាម ព្រះរាជបុត្រា ដើម្បីឱ្យអ្នករាល់គ្នាបានដឹងថាអ្នករាល់គ្នាមានជីវិតអស់កល្បជានិច្ចហើយ ។ (១យ៉ូហាន៥:១១_១៣)។

ចូរអរគុណព្រះជាញឹកញាប់ ដោយព្រោះព្រះគ្រីស្ទគង់ក្នុងជីវិតអ្នក និងដោយព្រោះព្រះអង្គពុំដែលបោះបង់ចោលអ្នកឡើយ (ហេព្រើរ១៣:៥)។ ដោយពឹងផ្អែកលើព្រះបន្ទូលសន្យារបស់ទ្រង់ អ្នកអាចដឹងថាព្រះគ្រីស្ទដ៏មានព្រះជន្មគង់នៅ ទ្រង់សណ្ឋិតក្នុងអ្នក ហើយក៏ដឹងថាអ្នកមានជីវិតអស់កល្បជានិច្ចចាប់តាំងពីពេលដែលអ្នកបានយាងព្រះអង្គ មកគង់ក្នុងជីវិតអ្នក។ ព្រះអង្គមិនកុហកឡើយ។





➢ *ការរំលឹកដ៏សំខាន់មួយ...*

**ចូរកុំពឹងផ្អែកលើអារម្មណ៍**

អំណាចដែលយើងអាចពឹងផ្អែកបាន ពុំស្ថិតនៅលើអារម្មណ៍របស់យើងទេតែស្ថិតលើសេចក្តីសន្យានៃព្រះបន្ទូលរបស់ទ្រង់វិញ។ គ្រីស្ទបរិស័ទរស់នៅដោយសារជំនឿ (ការទុកចិត្ត) ចំពោះព្រះគ្រីស្ទ និងព្រះបន្ទូលរបស់ព្រះអង្គដែលអាចឱ្យទុកចិត្តបាន។ រូបយន្តហោះនេះបង្ហាញពីការទាក់ទងរវាងសេចក្តីពិត (ព្រះ និងព្រះបន្ទូលរបស់ទ្រង់) ជំនឿ (ទំនុកចិត្តរបស់យើងចំពោះព្រះ និងព្រះបន្ទូលព្រះអង្គ) និងអារម្មណ៍ (លទ្ធផលនៃជំនឿនិងការស្តាប់បង្គាប់របស់យើង) (យ៉ូហាន១៤:២១)។



ដើម្បីធ្វើដំណើរតាមយន្តហោះ ជាចាំបាច់យើងត្រូវដាក់ជំនឿរបស់យើង ទៅលើយន្តហោះ និងអាកាសយានិក ដែលគួរឱ្យទុកចិត្តបាន។ អារម្មណ៍ឬក៏ភាពភ័យខ្លាចរបស់យើងវានឹងមិនមានឥទ្ធិពលលើសមត្ថភាពនៃយន្តហោះដែលដឹកជញ្ជូនយើងនោះឡើយ ទោះបីវាមានឥទ្ធិពលធ្វើឱ្យយើងរំភើបអរសប្បាយក្នុងការធ្វើដំណើរតាមយន្តហោះនេះក៏ដោយ។ ដូចគ្នាដែរយើងជាគ្រីស្ទបរិស័ទពុំអាចពឹងផ្អែកលើអារម្មណ៍ឬការរំភើបចិត្តបានឡើយ ប៉ុន្តែយើងត្រូវដាក់ជំនឿរបស់យើង (ទំនុកចិត្ត) ទៅលើព្រះ និងព្រះបន្ទូលសន្យារបស់ព្រះគ្រីស្ទដែលអាចឱ្យទុកចិត្តបាន។



**ឥឡូវនេះដែលអ្នកបានទទួលព្រះយេស៊ូវគ្រីស្ទហើយ**

នៅពេលដែលអ្នកបានទទួលព្រះយេស៊ូវគ្រីស្ទដោយជំនឿ នោះមានការជាច្រើនកើតឡើងរួមគ្នាជាមួយនឹងការខាងក្រោមនេះ÷

*១. ព្រះយេស៊ូវគ្រីស្ទបានយាងចូលក្នុងជីវិតអ្នក (វិវរណៈ៣:២០, កូល៉ុស១:២៧)*
*២. អ្នកបានទទួលនូវការអត់ទោសបាបពីព្រះ (កូល៉ុស១:១៤)*
*៣. អ្នកបានត្រឡប់ទៅជាកូនព្រះ (យ៉ូហាន១:១២)*
*៤. អ្នកបានទទួលនូវជីវិតអស់កល្បជានិច្ច (យ៉ូហាន៥:២៤)*
*៥. អ្នកបានចាប់ផ្តើមនូវជីវិតដ៏អស្ចារ្យមួយដែលព្រះទ្រង់សព្វព្រះហឫទ័យរៀបចំសំរាប់អ្នក (យ៉ូហាន១០:១០ ២កូរិនថូស៥:១៧ និង១ថែស្សាឡូនីច៥:១៨)*

*តើអ្នកអាចគិតឃើញថាមានអ្វីមួយដែលអស្ចារ្យជាងការដែលអ្នកបានទទួលព្រះយេស៊ូវគ្រីស្ទឬទេ? តើអ្នកចង់អរគុណព្រះដោយអធិស្ឋាន ចំពោះការដែលព្រះអង្គបានធ្វើសំរាប់អ្នកឬទេ? ការអរព្រះគុណព្រះនោះបង្ហាញនូវជំនឿរបស់អ្នក។*





➢ *សេចក្តីអំណរនៃទំនាក់ទំនងថ្មីរបស់អ្នកជាមួយព្រះ...*

**ការជួយគំនិតសម្រាប់ការចំរើនលូតលាស់នៃគ្រីស្ទបរិស័ទ**

ការចំរើនលូតលាស់ខាងព្រលឹងវិញ្ញាណ គឺជាលទ្ធផលនៃការទុកចិត្តលើព្រះយេស៊ូវគ្រីស្ទ។ «...មនុស្សសុចរិតនឹងរស់នៅដោយអាងជំនឿ» (កាឡាទី៣:១១)។ ជីវិតមានជំនឿ នឹងជួយឱ្យអ្នកចេះទុកចិត្តព្រះកាន់តែខ្លាំងឡើងជាលំដាប់ក្នុងគ្រប់ទាំងជំហាននៃជីវិតរបស់អ្នក ហើយអនុវត្តតាមដូចខាងក្រោមនេះ :

- ចូលទៅចំពោះព្រះរៀងរាល់ថ្ងៃដោយសេចក្តីអធិស្ឋាន (យ៉ូហាន១៥:៧)
- អានព្រះបន្ទូលព្រះរាល់ថ្ងៃ (កិច្ចការ១៧:១១) គឺចាប់ផ្តើមអានដំណឹងល្អយ៉ូហានជាដើម ។
- ស្តាប់បង្គាប់ព្រះគ្រប់ពេលវេលា (យ៉ូហាន១៤:២១)
- ធ្វើបន្ទាល់សំរាប់ព្រះគ្រីស្ទដោយការរស់នៅ និងដោយពាក្យសំដីរបស់អ្នក (ម៉ាថាយ៤:១៩ និងយ៉ូហាន១៥:៨)
- ទុកចិត្តព្រះក្នុងគ្រប់ជំហានជីវិតរបស់អ្នក (១ពេត្រុស៥:៧)
- ចំហចិត្តទទួលព្រះវិញ្ញាណបរិសុទ្ធឱ្យយាងចូលមកត្រួតត្រា និងប្រទានអំណាចដល់ការរស់នៅ និងដល់ការធ្វើបន្ទាល់ប្រចាំថ្ងៃរបស់អ្នក (កាឡាទី ៥:១៦_១៧ កិច្ចការ១:៨)។



## សារៈសំខាន់នៃពួកជំនុំល្អ

ហេព្រើរ (១០:២៥) បានចែងថាយើងមិនត្រូវបោះបង់ចោលការ «ប្រជុំគ្នា» របស់យើងទេ។ អង្កត់អុសច្រើនផ្តុំគ្នាទើបភ្លើងឆេះយ៉ាងសន្ធោសន្ធៅបាន ប៉ុន្តែបើដាក់អង្កត់អុសមួយ ដោយឡែកនៅលើដីត្រជាក់ ភ្លើងនៅអង្កត់អុសតែមួយនោះនឹងរលត់ជាមិនខាន។ ការទាក់ទងរបស់អ្នក និងគ្រីស្ទបរិស័ទដទៃទៀតក៏មានភាពដូចគ្នានេះដែរ។ សូមអញ្ជើញទៅព្រះវិហារដែលនៅជិតផ្ទះអ្នក ជាកន្លែងដែលគេតម្កើងព្រះគ្រីស្ទ និងសម្តែងព្រះបន្ទូលព្រះ។ សូមអ្នកចាប់ផ្តើមអញ្ជើញទៅព្រះវិហារនោះ នៅថ្ងៃអាទិត្យនេះ និងថ្ងៃអាទិត្យតទៅទៀតដោយទៀងទាត់។

*បើអ្នកចង់ស្វែងយល់បន្ថែម សូមទំនាក់ទំនងជាមួយ :*

ឈ្មោះ ____________________

អាស័យដ្ឋាន ____________________

ទូរស័ព្ទ __________ ទូរសារ __________

សូមដាក់ចូលក្នុងប្រអប់សំបុត្រលេខ
១៤០១ ភ្នំពេញ ១២០០០

១៦

ប្រសិនបើកូនសៀវភៅនេះមានន័យសម្រាប់ជីវិតអ្នកពិតប្រាកដមែន សូមបំពេញនូវទំព័រនេះ ដើម្បីឱ្យយើងដឹងពីមតិរបស់អ្នក។

- ☐ ខ្ញុំបានយាងព្រះយេស៊ូវគ្រីស្ទធ្វើជាព្រះអង្គសង្គ្រោះ និងជាព្រះអម្ចាស់របស់ខ្ញុំនៅថ្ងៃនេះ។
- ☐ ខ្ញុំជាគ្រីស្ទបរិស័ទរួចហើយ ខ្ញុំចង់រៀនបន្ថែមទៀត ប្រយោជន៍ឱ្យខ្ញុំស្គាល់ព្រះគ្រីស្ទកាន់តែច្បាស់។
- ☐ ខ្ញុំមានសំនួរខ្លះៗ សូមផ្ញើឯកសារដែលទាក់ទងនឹងអង្គបុគ្គលព្រះយេស៊ូវគ្រីស្ទ។

ឈ្មោះ ____________________

អាស័យដ្ឋាន ____________________

ទូរស័ព្ទ __________ ទូរសារ __________

១៧

**សូមចងចាំថា:**

ការចំរើនល្អគួរលាស់របស់អ្នកក្នុងការដើរជាមួយព្រះគ្រីស្ទ គឺពឹងផ្អែកទាំងស្រុងលើការដែលអ្នកអនុញ្ញាតឱ្យព្រះអង្គធ្វើការនៅក្នុងអ្នក និងតាមរយៈជីវិតអ្នក ដោយការប្រទានអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ ដែលមិនមែនជាការខិតខំប្រឹងប្រែងដោយកំលាំងផ្ទាល់ខ្លួនដើម្បីផ្គាប់ព្រះហឫទ័យទ្រង់នោះឡើយ ។

ជាការពិតណាស់ អ្នកអាចមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងព្រះ។ ព្រះអង្គសព្វព្រះហឫទ័យយ៉ាងខ្លាំងក្នុងការមានទំនាក់ទំនងផ្ទាល់ជាមួយលោកអ្នក ជាទំនាក់ទំនងនៃសេចក្តីស្រឡាញ់ ដែលទ្រង់បានរៀបចំរួចជាស្រេចសំរាប់អ្នក ។ ព្រះអង្គទ្រង់រង់ចាំអ្នកដោយព្រះហឫទ័យអត់ធ្មត់បំផុត អ្នកអាចទទួលបាននូវការអត់ទោសបាប ព្រមទាំងការធានានូវជីវិតអស់កល្បជានិច្ចតាមរយៈសេចក្តីជំនឿលើព្រះរាជបុត្រាទ្រង់តែមួយគត់គឺព្រះយេស៊ូវគ្រីស្ទ។

- ការដែលជារនាំងមិនឱ្យយើងមានទំនាក់ទំនងផ្ទាល់ជាមួយព្រះនោះគឺជាការដែលយើងមិនអើពើថាតើព្រះអង្គជានរណានិងថាតើព្រះអង្គបានធ្វើអ្វីខ្លះសំរាប់យើងទាំងអស់គ្នា
- សូមធ្វើការស្វែងយល់ដោយផ្ទាល់ខ្លួន ដើម្បីឱ្យបានទទួលនូវអំណរដ៏ពិតដែលបានមកពីការដែលមានទំនាក់ទំនងផ្ទាល់ជាមួយព្រះ